ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៤៤៤/២១ ក.ប/ស.ជ.ណ.ខ.ល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប ដែលស្ថិតនៅក្នុងតំបន់ក្រោមការអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំ នៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៥ ៤១៥នាក់ នៃរោងចក្រ សហគ្រាស ចំនួន ៧៤ ក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលស្ថិតនៅក្នុងតំបន់ក្រោមការអនុវត្តវិធានការបិទខ្ទប់ជាលក្ខណៈទ្រង់ទ្រាយធំនៃរាជធានីភ្នំពេញ ក្រុងតាខ្មៅនៃខេត្តកណ្តាល និងក្រុងព្រះសីហនុនៃខេត្តព្រះសីហនុ ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភចំនួន ១៦០ ០០០ (ដប់ប្រាំមួយម៉ឺន) រៀល តែមួយលើកគត់ ស្របតាមកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់របស់រាជរដ្ឋាភិបាល ទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាស នាពេលកន្លងមក។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ចំនួន ៧៤ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក ឬមានចម្ងល់ផ្សេងៗ នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម តាមរយៈក្រុមតេឡេក្រាម "សម្រាប់កម្មករនិយោជិត" https://t.me/KhmerWorkerChat។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ អង្គារ ១៤កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២១
រដ្ឋមន្ត្រី

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១

បញ្ជីឈ្មោះរោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប នៅក្នុងតំបន់ក្រោមការអនុវត្តវិធានការបិទខ្ទប់ ចំនួន ៧៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| សរុបរួម | | 74 |
| 1 | ពូស៊ុង ហ្គាម៉ិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 2 | ហ្វ័រគ្រេស អ៊ិនធើណេសិនណល ឯ.ក | ភ្នំពេញ |
| 3 | អិមអេច ឡាបែល (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 4 | សានស៊ូ ខ្លូស៊ីង (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 5 | អេចខេ ប៉ុលតិច មេនូហ្វេកធើរី ឯ.ក | ភ្នំពេញ |
| 6 | ម៉ារ័ល ហ្គាមិន ឯ.ក | ភ្នំពេញ |
| 7 | សាន់ វើលដ៍ ហ្គាមេន | ភ្នំពេញ |
| 8 | ជី-អេវើរហ្គ្រេត (ខេមបូឌា) នីតធីង ឯ.ក | ភ្នំពេញ |
| 9 | ហ្គ្រេន ស្កាយ (ខេមបូឌា) ហ្គាម៉ិន | ភ្នំពេញ |
| 10 | ខេមបូ អេច.ឌី.វ៉ាយ.អិល ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 11 | ហ៊ី ហ្វុង អ៊ីនធើប្រាយ ឯ.ក | ភ្នំពេញ |
| 12 | ហេង យុន វ៉ាង (ខេមបូឌា) ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 13 | ម៉ាកស៍ វូ ថេកស្តាយ (ខេមបូឌា) | ភ្នំពេញ |
| 14 | ដុក វ៉ូ (ខេមបូឌា) | ភ្នំពេញ |
| 15 | សៃអឺ (ខេមបូឌា) ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 16 | ហេង ស្គូវៀ ថេកស្តាយ | ភ្នំពេញ |
| 17 | ហ្វ្រិនទ្រី ខេម ហ្គាមេន | ភ្នំពេញ |
| 18 | ស៊ីង ឡុង ឆបភីង បត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 19 | ជីក្វាន អ៊ិនធើណេសិនណល (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 20 | ស៊ីន ហ្វូពីង ស៊ូ មេធៀរៀល | ភ្នំពេញ |
| 21 | ម៉ុនទី អឺភែរីល (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 22 | ហុង ឆាង ជី អ៊ី ឆាង ឯ.ក | ភ្នំពេញ |
| 23 | ឡេវ៉ឺល អាប់ លេបឺល (ខេមបូឌា) អិលធីឌី | ភ្នំពេញ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 24 | ស៊ិន លាន ស៊ិន អេឡិស្ទីត & ស្រ្ទីង (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 25 | ឌូក វើលដ៍ ថយស៍ ឯ.ក | ភ្នំពេញ |
| 26 | វ៉េដ គ្លូបល អ៊ីគែវីល ឯ.ក | ភ្នំពេញ |
| 27 | មូន អ៊ីគែវីល (ខេមបូឌា) | ភ្នំពេញ |
| 28 | បូអ៊ី ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 29 | ញូ វ៉ាយដ៍ (ខេមបូឌា) ហ្គាមេន | ភ្នំពេញ |
| 30 | អេផិច អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី | ភ្នំពេញ |
| 31 | អេវើរគ្រីន ហ្គាមេន ខូ អេលធីឌី | ភ្នំពេញ |
| 32 | ហៃ ហ្វី ហ្គាមេនហ្វេកធើរី | ភ្នំពេញ |
| 33 | វ៉ានហុង(ខេមបូឌា)ហ្គាមេន សាខាទី២ | ភ្នំពេញ |
| 34 | អាសៀណា ហ្គាម៉ិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 35 | យូនីប្រូស (ខេមបូឌា) អេនធើប្រាយ | ភ្នំពេញ |
| 36 | ស៊ីង ស៊ុន ហ្វា ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 37 | លីឌីង ស្តារ (ខេមបូឌា) ហ្គាម៉ិន ឯ.ក (សាខាភ្នំពេញ) | ភ្នំពេញ |
| 38 | អេវើមេកស៍ ហ្គាមេន អេកសេស៊ីរី (ខេមបូឌា) | ភ្នំពេញ |
| 39 | ម៉ូហ្វាស (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 40 | តាវ អេន ឃីវិន ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 41 | ហ៊ូលូ ហ្គាមេន | ភ្នំពេញ |
| 42 | ស្ព័ត ប្រជាក់ (ខេមបូឌា) ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 43 | អូរៀន ហុងយេ (ខេមបូឌា) នីតធីង ឯ.ក | ភ្នំពេញ |
| 44 | ស៊ូវ ហ្គូដ ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 45 | ដាប់ប៊ែលយូ អេច កាត់ដេរ | ភ្នំពេញ |
| 46 | នីច-ធី អ៊ីគែវីល (ខេមបូឌា) | ភ្នំពេញ |
| 47 | ដាប់បែលយូ អ៊ីមប៊ែលលីសមេន អិលធីឌី | ភ្នំពេញ |
| 48 | អ៊ីស៊ីន ចាំង ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 49 | នីអាន់ ឃីដ (ខេមបូឌា) (សាខាទី២) | ភ្នំពេញ |
| 50 | អេវើ ស៊ូប្រា ហ្គាមេន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 51 | ហេង យ៉ុន | ភ្នំពេញ |
| 52 | ស៊ីធី ស្ប៉ាក (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 53 | វ៉ាន់ហុង (ខេមបូឌា) ហ្គាមេន សាខាទី១ | ភ្នំពេញ |
| 54 | សិប្បកម្ម ស៊ុនស៊ីងលិ | ភ្នំពេញ |
| 55 | ស្តាយ បេស ហ្វេសិន ឯ.ក | ភ្នំពេញ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 56 | ចៅ លីន (ខេមបូឌា) ឯ.ក. | ភ្នំពេញ |
| 57 | ហុង រួយ ជា ប្រូសេស៊ីង ហ្វេកធើរី ឯ.ក | ភ្នំពេញ |
| 58 | ចានយ៉ន (ខេមបូឌា) ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 59 | ហេន ស៊ើវេន អឹរែរឹល | ភ្នំពេញ |
| 60 | សិប្បកម្ម ទន់ ស៊ីថា | ភ្នំពេញ |
| 61 | ហ្វាង ស៊ីង ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 62 | គ្រីអេធីវ អូ ស៊ុង ឯ.ក | ភ្នំពេញ |
| 63 | ញូ វីស អ៊ិនដាសស្ទ្រៀល | ភ្នំពេញ |
| 64 | ស៊ីន វេន ហ្គួយ ថេលើរីង ស៊ីវីស ឯ.ក | ភ្នំពេញ |
| 65 | អ៊ីយ៉ីង (ខេមបូឌា) អ៊ិនដាសស្ទ្រៀល ឯ.ក | ភ្នំពេញ |
| 66 | អាយជីធីអិម (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 67 | ញូ អេរ៉ា (ខេមបូឌា) ខាសមៀ ថិកស្ដាយ៍ ឯ.ក | កណ្ដាល |
| 68 | ហ្វូជាន ម៉ីលីដា ស៊ូ ឌីវេឡុបម៉ិន ឯ.ក | កណ្ដាល |
| 69 | យូ-នីត (ខេមបូឌា) | កណ្ដាល |
| 70 | ជីវ ហ្ស៊ី ហ្គាម៉ិន ឯ.ក | កណ្ដាល |
| 71 | ជាំងស៊ី ពាអិល មេឌីខល ប្រដាក់ គ្រុប (ខេមបូឌា) | ព្រះសីហនុ |
| 72 | ខេមបូឌាន ចាន ស៊ីន ហៅហ្វូល ប្រូដាក់ស៍ | ព្រះសីហនុ |
| 73 | ហ្ស៊ីជាង ហ្វូម ភ័ញ ហ្វើនីឈ័រ ឯ.ក | ព្រះសីហនុ |
| 74 | ផេកជីវ អ៊ិនធើណេសិនណាល (ខេមបូឌា) | ព្រះសីហនុ |